ភ្នំពេញ ថ្ងៃទី ២២ ខែមិថុនា ឆ្នាំ២០១៦

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## សិក្ខាសាលាស្តីពី "អនុលោមភាពពន្ធ ចំពោះគណនីក្រៅប្រទេសរបស់អាមេរិក ( Foreign Account Tax Compliance Act-FATCA )"




© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

នៅវេលាម៉ោង ០៩:០០ នាទី ព្រឹកថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៦នៅសណ្ឋាគារដារាអ៊ែរផតមានបើកសិក្ខាសាលាស្តីពី អនុលោមភាពពន្ធ ចំពោះគណនីក្រៅប្រទេសរបស់អាមេរិក ដែលរៀបចំឡើង ក្រោមកិច្ចសហការរវាងអគ្គនាយកដ្ឋានពន្ធដារ និងសមាគមធនាគារនៅកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ និងជាសហប្រធានក្រុមការងារ អគ្គនាយកដ្ឋានពន្ធដារ និងផ្នែកឯកជន ដើម្បីសម្របសម្រួលការងារ FATCA និង លោក **វ៉ាន់ ឆារស៍** ប្រធានស្តីទី សមាគមធនាគារនៅកម្ពុជា និងជាសហប្រធានក្រុមការងារ អគ្គនាយកដ្ឋានពន្ធដារ និងផ្នែកឯកជន ដើម្បីសម្របសម្រួលការងារ FATCA ដោយមានការចូលរួមធ្វើបទបង្ហាញពីវាគ្មិនមកពី ធនាគារយូណាយធីត អូវើស៊ី នៃប្រទេសសិង្ហបុរី (United Overseas Bank–UOB) ព្រមទាំងមានការចូលរួមពីសំណាក់ ឯកឧត្តម លោកឧកញ៉ា លោកជំទាវ លោក លោកស្រី ដែលមកពីអគ្គនាយកដ្ឋានពន្ធដារ និងស្ថាប័នហិរញ្ញវត្ថុនានាជាច្រើនរូបទៀត។

ជាកិច្ចចាប់ផ្តើម ឯកឧត្តម គង់ វិបុល និងលោក វ៉ាន់ ឆារស៍ បានថ្លែងសុន្ទរកថា បើកអង្គសិក្ខាសាលា និងសម្តែងនូវកិច្ចស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះវត្តមានរបស់អ្នកចូលរួមទាំងអស់ ដែលបានឆ្លៀតយកពេលវេលាដ៏មានតម្លៃ ចូលរួមក្នុងសិក្ខាសាលាដំបូងស្តីពី FATCA ដ៏មានសារប្រយោជន៍ដែលរៀបចំដោយអគ្គនាយកដ្ឋានពន្ធដារ និងសមាគមធនាគារកម្ពុជានេះ ជាសក្ខីកម្មបញ្ជាក់ពីការយកចិត្តទុកដាក់ ស្វែងយល់អំពីការ

អនុវត្តច្បាប់ អនុលោមភាពពន្ធចំពោះគណនីក្រៅប្រទេសរបស់អាមេរិក។

ឯកឧត្តមប្រតិភូបានបញ្ជាក់ថា FATCA គឺជាច្បាប់របស់សហរដ្ឋអាមេរិក ដែលបង្កើតឡើងក្នុងគោលបំណង កាត់បន្ថយការគេចវេះពន្ធ ដោយពលរដ្ឋ និវាសនជន និងនីតិបុគ្គលអាមេរិក ដែលមានគណនីនៅក្រៅប្រទេស។ ច្បាប់ FATCA តម្រូវឱ្យស្ថាប័នហិរញ្ញវត្ថុទូទាំងពិភពលោកចុះឈ្មោះ និងរាយការណ៍ជាប្រចាំ ដល់អាជ្ញាធរពន្ធដារអាមេរិក (Internal Revenue Services) នូវព័ត៌មានហិរញ្ញវត្ថុទាំងអស់របស់ពលរដ្ឋ និវាសនជន និងនីតិបុគ្គលអាមេរិក ដែលមានចែងនៅក្នុងច្បាប់ FATCA នេះ។ ការមិនអនុលោមភាពតាមច្បាប់ FATCA ស្ថាប័នហិរញ្ញវត្ថុពាក់ព័ន្ធនឹង ប្រឈមការផាកពិន័យ ដោយការកាត់ទុកពន្ធ ៣០% លើតម្លៃដុលនៃប្រតិបត្តិការហិរញ្ញវត្ថុ។

ដើម្បីសម្រួលដល់វិស័យឯកជន ឲ្យមានអនុលោមភាព FATCA រដ្ឋាភិបាលកម្ពុជា បានចុះហត្ថលេខាជាមួយសហរដ្ឋ-អាមេរិក លើកិច្ចព្រមព្រៀងនេះ កាលពីថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥។ កិច្ចព្រមព្រៀងនេះ អនុញ្ញាតឲ្យស្ថាប័នហិរញ្ញវត្ថុទាំងអស់មានកាតព្វកិច្ច ផ្តល់ព័ត៌មានដែលតម្រូវក្រោមច្បាប់ FATCA មកអាជ្ញាធរមាន សមត្ថកិច្ចកម្ពុជា (អគ្គនាយកដ្ឋានពន្ធដារ) ដើម្បីពិនិត្យបញ្ជាក់ មុននឹងបញ្ជូនបន្តទៅ អាជ្ញាធរពន្ធដារអាមេរិក។

សិក្ខាសាលាដែលមានរយៈពេលពីរថ្ងៃនេះ រៀបចំឡើងក្នុងគោលបំណងផ្តល់ជា បទបង្ហាញស្តីពីតម្រូវការនានា ទាក់ទងនឹងច្បាប់ FACTA និងដំណើរការប្រតិបត្តិការ ក្នុងការអនុវត្ត



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

ដល់មន្ត្រីទទួលបន្ទុកការងារFATCAនៃអគ្គនាយកដ្ឋានពន្ធដារ ក៏ដូចជាស្ថាប័នហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា។ ជាមួយគ្នានេះ សិក្ខាសាលានឹងជួយ ត្រួសត្រាយផ្លូវ សម្រាប់កិច្ចសហប្រតិបត្តិការរវាងអគ្គនាយកដ្ឋានពន្ធដារ និងស្ថាប័ន ហិរញ្ញវត្ថុនៅកម្ពុជា ក្នុងការអនុវត្តច្បាប់ FATCA។

ជាទីបញ្ចប់ឯកឧត្តម គង់ វិបុល ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ បានថ្លែងអំណរគុណដល់សមាគមធនាគារនៅកម្ពុជា ដែលបានផ្តល់នូវកិច្ចសហការដ៏ជិតស្និទ្ធក្នុងការរៀបចំសិក្ខាសាលា ដ៏មានសារៈសំខាន់នេះឡើង និងថ្លែងអំណរគុណដល់វាគ្មិនមកពីប្រទេសសិង្ហបុរី ដែលបានមកចែករំលែកចំណេះដឹង និងបទពិសោធន៍ទាក់ទងនឹងការអនុវត្តច្បាប់ FATCAដល់សិក្ខាកាមទាំងអស់។ ឯកឧត្តមក៏បានជូនពរដល់អង្គសិក្ខាសាលាទាំងមូល ឱ្យសមប្រកបនឹងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ៕


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ